ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ០៣៦២ សនក.ប្រក

# ប្រកាស
# ស្តីពី
# ការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៦/០១៣ ចុះថ្ងៃ០៩ ខែសីហា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំ កោសិកា ជាលិកា និងសរីរាង្គមនុស្ស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៦/០១៤ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣ ស្តីពីក្រមសីលធម៌គ្រូពេទ្យ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីក្រមសីលធម៌ទន្តពេទ្យ



អាសយដ្ឋាន៖ ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីម៉ែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia

- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ស្តីពីក្រមសីលធម៌ធ្មប
- បានឃើញអនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ស្តីពីក្រមសីលធម៌ឱសថការី
- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីក្រមសីលធម៌គិលានុបដ្ឋាក
- បានឃើញអនុក្រឹត្យលេខ២៣៩ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីគ្រប់គ្រងការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាលប្រកបដោយសុចរិតភាព ដើម្បីធានាគុណភាពនៃការផ្តល់សេវាសុខាភិបាល និងសុវត្ថិភាពជូនប្រជាជនក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងមូលដ្ឋានសុខាភិបាលឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះត្រូវកំណត់និយមន័យដូចតទៅ៖

- **ក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល** សំដៅដល់ប្រភេទសេវាឬជំនាញឯកទេស និងការអប់រំសុខភាព ឬវិជ្ជាជីវៈដែលពាក់ព័ន្ធនឹងជំនាញសុខាភិបាល។
- **ការប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់ការអនុវត្តវិជ្ជាជីវៈដែលស្ថិតក្នុងដែនកំណត់វិជ្ជាជីវៈសុខាភិបាលនៃមុខវិជ្ជាជីវៈសុខាភិបាលនីមួយៗ។
- **អ្នកវិជ្ជាជីវៈសុខាភិបាល** សំដៅដល់គ្រូពេទ្យ ទន្តពេទ្យ ធ្មប គិលានុបដ្ឋាក ឱសថការី អ្នកបច្ចេកទេសមន្ទីរពិសោធន៍សុខាភិបាល អ្នកព្យាបាលដោយចលនា ទន្តគិលានុបដ្ឋាក អ្នកបច្ចេកទេសវិទ្យុសាស្ត្រ និងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតដែលទទួលបានការចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ។
- **អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់អ្នកវិជ្ជាជីវៈសុខាភិបាលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈស្របតាមច្បាប់ស្តីពីការគ្រប់គ្រងអ្នកវិជ្ជាជីវៈវិស័យសុខាភិបាល។
- **មូលដ្ឋានសុខាភិបាល** សំដៅដល់ទីកន្លែងផ្តល់សេវាសុខាភិបាលទាំងអស់ ដែលមានជាអាទិ៍មូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន អង្គការ និងសមាគមដែលផ្តល់សេវាសុខាភិបាល មានទីតាំងជាប់លាប់ ឬមិនជាប់លាប់។

- **មូលដ្ឋានសុខាភិបាលឯកជន** រួមមាន មន្ទីរពេទ្យ មន្ទីរពេទ្យឯកទេស មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្រាកព្យាបាលឯកទេស មន្ទីរសម្ភព-រោគស្ត្រី មន្ទីរព្យាបាលជំងឺមាត់-ធ្មេញ មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មណ្ឌលកែសម្ផស្ស មណ្ឌលលាងឈាម មណ្ឌលរោគវិនិច្ឆ័យ ការិយាល័យតំណាងមន្ទីរពេទ្យ មណ្ឌលរូបភាពវេជ្ជសាស្ត្រ មណ្ឌលថែរក្សាសម្ផស្ស មណ្ឌលព្យាបាលដោយចលនា បន្ទប់ថែទាំជំងឺ បន្ទប់ថែទាំមាត់-ធ្មេញ បន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះមុននិងក្រោយសម្រាល បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញ បន្ទប់ពិគ្រោះព្យាបាលជំងឺទូទៅ បន្ទប់ពិគ្រោះព្យាបាលឯកទេស និងសេវាគិលានសង្គ្រោះមិនមែនសាធារណៈ។
- **មណ្ឌលរោគវិនិច្ឆ័យវេជ្ជសាស្ត្រ** សំដៅដល់មូលដ្ឋានសុខាភិបាលដែលផ្តល់សេវាពិនិត្យ និងធ្វើវិនិច្ឆ័យជំងឺដោយប្រើបច្ចេកវិទ្យាវេជ្ជសាស្ត្រទំនើប និងវិធីសាស្ត្រវេជ្ជសាស្ត្រផ្សេងៗ។
- **មណ្ឌលរូបភាពវេជ្ជសាស្ត្រ** សំដៅដល់ផ្នែកមួយនៃមណ្ឌលធ្វើរោគវិនិច្ឆ័យវេជ្ជសាស្ត្រ ដែលផ្តល់សេវាការពិនិត្យជំងឺដោយប្រើបច្ចេកវិទ្យារូបភាពវេជ្ជសាស្ត្រ។
- **សេវាសុខាភិបាល** សំដៅដល់ការងាររៀបចំ ចាត់ចែង ពិគ្រោះ ពិនិត្យ វិភាគ បង្ការ ធ្វើរោគវិនិច្ឆ័យ ព្យាបាល ថែទាំ អប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ ឬប្រើប្រាស់មធ្យោបាយផ្សេងៗ ក្នុងគោលបំណងលើកកម្ពស់គុណភាព សុវត្ថិភាព សុខភាព និងសុខុមាលភាព។

## ជំពូកទី២
## សមត្ថកិច្ច

**ប្រការ៤ .-**

ការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាលដែលមិនប៉ះពាល់ដល់ក្រមសីលធម៌ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ដោយដាក់ពាក្យស្នើសុំតាមរយៈច្រកចេញចូលតែមួយរបស់ក្រសួងសុខាភិបាល។

**ប្រការ៥ .-**

អ្នកទទួលខុសត្រូវមូលដ្ឋានសុខាភិបាលឯកជន អង្គការ និងសមាគមដែលផ្តល់សេវាសុខាភិបាលដែលមានបំណងផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាលតម្រូវឱ្យដាក់ពាក្យស្នើសុំមកក្រសួងសុខាភិបាល។

## ជំពូកទី៣
## បែបបទស្នើសុំផ្សព្វផ្សាយ

**ប្រការ៦ .-**

អ្នកទទួលខុសត្រូវមូលដ្ឋានសុខាភិបាលដែលមានបំណងផ្សព្វផ្សាយ តម្រូវឱ្យភ្ជាប់មកជាមួយនូវខ្លឹមសារអត្ថបទ និង/ឬរូបភាព និង/ឬស្ប៉តវីដេអូ និង/ឬសេណារីយ៉ូ និង/ឬសោតទស្សន៍ជាឯកសារទន់(Soft Copy) និងឯកសាររឹង(Hard Copy) ព្រមជាមួយឯកសារយោងដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយ។

មូលដ្ឋានសុខាភិបាលឯកជនដែលមានបំណងធ្វើការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាលទោះក្នុងរូបភាពចែករំលែកចំណេះដឹង ឬការអប់រំថែទាំសុខភាពក៏ដោយ លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាលទើបធ្វើការផ្សព្វផ្សាយបាន។

**ប្រការ៧ ._**

អ្នកទទួលខុសត្រូវមូលដ្ឋានសុខាភិបាលឯកជនអាចស្នើសុំធ្វើការផ្សព្វផ្សាយពីទីតាំង និងសេវាសុខាភិបាលរបស់ខ្លួនបាន នៅពេលបើកទីតាំងថ្មី ផ្លាស់ប្តូរទីតាំង ផ្លាស់ប្តូរឬបន្ថែមមុខជំនាញ ឬស្នើសុំបន្តសុពលភាពអំពីការអនុញ្ញាតផ្សព្វផ្សាយដែលបានទទួលរួចហើយ។

**ប្រការ៨ ._**

ទម្រង់គំរូសម្រាប់ការស្នើសុំផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាលដែលមិនប៉ះពាល់ដល់ក្រមសីលធម៌វិជ្ជាជីវៈ រួមមានពាក្យស្នើសុំនិងកិច្ចសន្យាធានាអះអាងមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៩ ._**

បន្ទាប់ពីបានឆ្លងកាត់ការត្រួតពិនិត្យរួច ក្រសួងសុខាភិបាលនឹងផ្តល់ការអនុញ្ញាតឱ្យចុះផ្សាយជាសាធារណៈបានដូចខាងក្រោម៖

១- នាម-គោត្តនាម អាសយដ្ឋាន លេខទូរស័ព្ទ ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀត ពេលវេលាទទួលពិគ្រោះព្យាបាលរបស់អ្នកប្រកបវិជ្ជាជីវៈ។

២- គុណវុឌ្ឍិ រួមមានសញ្ញាប័ត្រ និងសមត្ថភាពផ្សេងៗ ទទួលស្គាល់ដោយក្រសួងសុខាភិបាល។

៣- ស្ថានភាពសេវា និងអ្នកផ្តល់សេវា។

៤- ភាពជាដៃគូសេវាជានាក់ព័ន្ធរវាងសុខភាពសាធារណៈនិងឯកជន បើមាន។

៥- ខ្លឹមសារផ្សព្វផ្សាយផ្សេងៗទៀត ដែលទទួលបានអនុញ្ញាតពីក្រសួងសុខាភិបាល។

**ប្រការ១០ ._**

សុពលភាពនៃលិខិតអនុញ្ញាតផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល៖

១- តាមរយៈវិទ្យុ ទូរទស្សន៍ ប្រព័ន្ធអេឡិចត្រូនិក គេហទំព័រ និងបណ្តាញសង្គមផ្សេងៗ មានជាអាទិ៍ ហ្វេសប៊ុក តិកតុក តេឡេក្រាម អ៊ីនស្តាក្រាម យូធូប ប្រព័ន្ធផ្សព្វផ្សាយអ៊ិច ព្រមទាំងសារព័ត៌មានទស្សនាវដ្តី ព្រឹត្តិបត្រវេជ្ជសាស្ត្រ ប្រតិទិន ប័ណ្ណប្រកាសរូបភាព ខិត្តប័ណ្ណ និងសម្ភារៈគ្រប់ប្រភេទ ផ្ទាំងរូបភាពធំៗ ផ្ទាំងរូបភាពអគ្គិសនី(LED) និងការផ្សព្វផ្សាយដោយប្រើឧបករណ៍បំពងសំឡេងតាមទីសាធារណៈ មធ្យោបាយធ្វើដំណើរ ឬតាមរូបភាពផ្សេងៗ មានសុពលភាពរយៈពេល១២ខែ។

២- តាមរយៈសិក្ខាសាលា ឬប្រជុំតុមូល ការតាំងពិព័រណ៍គ្រប់ប្រភេទមានសុពលភាព១លើក មិនឱ្យលើសពី៧ថ្ងៃ ។

ការស្នើសុំបន្តសុពលភាពឡើងវិញនៅចំណុចទី១នៃប្រការនេះ តម្រូវឱ្យដាក់ពាក្យស្នើសុំឱ្យបានយ៉ាងតិច ២ខែ មុនពេលអស់សុពលភាព។

**ប្រការ១១ .-**

ហាមឃាត់រាល់ការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល ដូចខាងក្រោម៖

- ការប្រើពាក្យពេចន៍លើកតម្កើងខ្លួនតែមួយ ឬប្រកួតប្រជែង វាយប្រហារ ដើម្បីផ្តល់សេវាកម្មរបស់មូលដ្ឋានសុខាភិបាលផ្សេងទៀត
- ការប្រឌិត ឬបំភ្លៃការពិតប្រាសចាកពីក្រមសីលធម៌វិជ្ជាជីវៈសុខាភិបាល ធ្វើជាមុខជំនួញផ្ទាល់ខ្លួនណាមួយ តាមរូបភាពផ្សព្វផ្សាយដោយផ្ទាល់ ឬដោយប្រយោល តាមរូបភាពសម្ភាសអតិថិជន ឬអ្នកជំងឺ
- ការផ្សព្វផ្សាយដែលប៉ះពាល់ដល់ក្រមសីលធម៌វិជ្ជាជីវៈ
- ការផ្សព្វផ្សាយ ឬការផ្សាយផ្ទាល់ (LIVE) ឬផ្សាយបន្តផ្ទាល់នានា ឬចែករំលែកបន្ត (SHARE) ជាសាធារណៈ អំពីរោគសញ្ញាគ្លីនិកនៃជំងឺ និងវិធីព្យាបាលណាមួយ ដែលមានលក្ខណៈបំផ្លើស បោកប្រាស់អតិថិជន ឬមានលក្ខណៈពាណិជ្ជកម្មដែលប៉ះពាល់ដល់ក្រមសីលធម៌វិជ្ជាជីវៈ
- ការបំពាននឹងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត។

**ប្រការ១២ .-**

មិនអនុញ្ញាតឱ្យមូលដ្ឋានសុខាភិបាលប្រើប្រាស់ឈ្មោះមូលដ្ឋានសុខាភិបាលដទៃឬឈ្មោះអ្នកឯកទេសសហការជាមួយគ្នា ទោះជាបរទេសក្តី ក្នុងរូបភាពក្លែងបន្លំ ដែលមានគោលបំណងឃោសនាផ្សព្វផ្សាយពាណិជ្ជកម្មដែលប៉ះពាល់ដល់ក្រមសីលធម៌វិជ្ជាជីវៈ។

**ប្រការ១៣ .-**

ក្រសួងសុខាភិបាលមានសិទ្ធិលុបលិខិតអនុញ្ញាតផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល ក្នុងករណីពិនិត្យឃើញថាខ្លឹមសារផ្សព្វផ្សាយមានលក្ខណៈខុសពីការអនុញ្ញាតរបស់ក្រសួងសុខាភិបាល ឬការផ្សព្វផ្សាយនោះអាចបង្កបាតុភាពមិនល្អផ្សេងៗ។

មូលដ្ឋានសុខាភិបាលដែលបានប្រព្រឹត្តកំហុសឆ្គងក្នុងការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល អាចប្រឈមនឹងទណ្ឌកម្មដូចខាងក្រោម៖

- ធ្វើការព្រមានជាលាយលក្ខណ៍អក្សរ
- ព្យួរលិខិតអនុញ្ញាតមូលដ្ឋានសុខាភិបាលជាបណ្តោះអាសន្ន
- លុបលិខិតអនុញ្ញាតមូលដ្ឋានសុខាភិបាលជាស្ថាពរ។

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលបានប្រព្រឹត្តកំហុសឆ្គងក្នុងការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាលអាចប្រឈមនឹងទណ្ឌកម្មដែលកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ។

**ប្រការ១៤ .-**

ការសម្រេចដាក់ទណ្ឌកម្មស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ មិនមែនជាឧបសគ្គដល់ការចោទប្រកាន់និងផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានឡើយ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១៥ .-**

ប្រកាសលេខ០២៨ អ.ប.ស.ម.ព ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤ ស្តីពីការផ្សព្វផ្សាយជាលក្ខណៈវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦ .-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល គ្រប់ប្រធាននាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៥ កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាង រ៉ា**

**<u>កន្លែងទទួល៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ០៣៦២សសកប្រ ចុះថ្ងៃទី២៤ ខែ...ធ្នូ......ឆ្នាំ២០២៥ ស្តីពីការ
ផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល

**ទម្រង់គំរូពាក្យស្នើសុំលិខិតអនុញ្ញាតផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំលិខិតអនុញ្ញាតការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..........................................អាយុ......................ឆ្នាំ ភេទ.................សញ្ជាតិ...................
ជាអ្នកទទួលខុសត្រូវ មន្ទីរ.......................................................................ឈ្មោះ......................................................
ដែលមានទីតាំងស្ថិតនៅផ្ទះ.................................ផ្លូវ...............................................ឃុំ/សង្កាត់.......................................
ក្រុង/ស្រុក/ខណ្ឌ...................................................រាជធានី/ខេត្ត.............................................ដែលក្រសួងបានចេញលិខិត
អនុញ្ញាតលេខ..............................ចុះថ្ងៃទី..........ខែ..............ឆ្នាំ២០២......ទូរសព្ទទំនាក់ទំនង.......................................

**សូមគោរពជូន**
**ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**កម្មវត្ថុ៖** សំណើសុំការអនុញ្ញាតផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល ។

ខ្ញុំបាទ-នាងខ្ញុំ មានបំណងធ្វើការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល អំពី.......................................................
...........................................................................................................................................................................
តាម...........................................................ប៉ុស្តិ៍វិទ្យុ ឬទូរទស្សន៍លេខ ឬគណនីឈ្មោះ..................................................................
និងតំណភ្ជាប់.....................................................................................................................................................។

សូម **ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល** មេត្តាអនុញ្ញាតឱ្យខ្ញុំបាទ-នាងខ្ញុំធ្វើការផ្សព្វផ្សាយ ដោយក្តីអនុគ្រោះ។

សូមភ្ជាប់មកជាមួយនូវ៖

- -ច្បាប់ចម្លងលិខិតអនុញ្ញាតដែលក្រសួងសុខាភិបាលចេញឱ្យបើកទីតាំងផ្តល់សេវា.............................................០១ច្បាប់
- -កិច្ចសន្យាធានាអះអាង..........................................................................................................................០១ច្បាប់
- -ខ្លឹមសារអត្ថបទ រូបភាព សោតទស្សន៍ ឬវីដេអូផ្សព្វផ្សាយ.........................................................................០១ច្បាប់ ។

សូម **ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ.................................ខែ...............ឆ្នាំ.........................ព.ស. ២៥៦......
ធ្វើនៅ............................ថ្ងៃទី.............ខែ.................ឆ្នាំ២០២.......

**ហត្ថលេខា**

ឧបសម្ព័ន្ធ នៃប្រកាសលេខ០៣៦២សនភឃបគ ចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០២៥ ស្ដីពីការ
ផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈសុខាភិបាល

**ទម្រង់គំរូកិច្ចសន្យាធានាអះអាង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យាធានាអះអាង

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.................................................អក្សរឡាតាំង.................................................អាយុ...........ឆ្នាំ
ជនជាតិ...........សញ្ជាតិ.............ជាអ្នកទទួលខុសត្រូវសេវា.................................................ឈ្មោះ.................................
មានទីលំនៅបច្ចុប្បន្នផ្ទះ.......................ផ្លូវ.........................ឃុំ/សង្កាត់..............................ក្រុង/ស្រុក/ខណ្ឌ................................
ខេត្ត/រាជធានី....................................ទូរសព្ទលេខ:...............................E-mail: ...................................................

សូមធានាអះអាងចំពោះមុខក្រសួងសុខាភិបាលថា ខ្ញុំបាទ-នាងខ្ញុំនឹង ៖

- គោរពឱ្យបានត្រឹមត្រូវនូវច្បាប់ អនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំផ្សេងៗរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល
- គោរពច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ក្នុងព្រះរាជាណាចក្រកម្ពុជា
- គោរពច្បាប់ស្តីពីការគ្រប់គ្រងលើអ្នកប្រកបវិជ្ជាជីវៈក្នុងវិស័យសុខាភិបាល
- មិនធ្វើការផ្សព្វផ្សាយជាលក្ខណៈផ្សាយពាណិជ្ជកម្ម និងដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាលប្រាសចាកពីក្រមសីលធម៌វិជ្ជាជីវៈ
- មិនផ្សព្វផ្សាយ ផ្សាយបន្តផ្ទាល់នានា អំពីរោគសញ្ញាគ្លីនិកនៃជំងឺ និងវិធីព្យាបាលណាមួយ ដែលមានលក្ខណៈបំផ្លើសបោកប្រាស់អតិថិជន ឬមានលក្ខណៈពាណិជ្ជកម្ម
- មិនផ្សព្វផ្សាយដោយប្រើប្រាស់ឈ្មោះមន្ទីរពេទ្យ ឬគ្លីនិកឯកជន អ្នកឯកទេសសហការជាមួយគ្នា ទោះជាបរទេសក្តី ក្នុងរូបភាពក្លែងបន្លំដែលមានគោលបំណងឃោសនាផ្សព្វផ្សាយពាណិជ្ជកម្មដែលប៉ះពាល់ដល់ក្រមសីលធម៌វិជ្ជាជីវៈ
- ខ្លឹមសារផ្សព្វផ្សាយ ត្រូវមានលក្ខណៈត្រឹមត្រូវ តាមឯកសារវិទ្យាសាស្ត្រសុខាភិបាល ចៀសវាងការឃោសនាបំផ្លើសប្រាសចាកខុសពីខ្លឹមសារដែលមានការអនុញ្ញាតពីក្រសួងសុខាភិបាល
- ផ្សព្វផ្សាយតែអ្វីដែលក្រសួងសុខាភិបាលបានអនុញ្ញាត រាល់ខ្លឹមសារអត្ថបទ ស្ប៉តវីដេអូ ឬកាសែតសោតទស្សន៍ និងរូបភាពដែលធ្វើបច្ចុប្បន្នភាពថ្មី ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាល
- មិនប្រើពាក្យពេចន៍លើកតម្កើងខ្លួនតែមួយ ឬប្រកួតប្រជែង វាយប្រហារ ដើម្បីផ្តួលសេវាកម្មរបស់មូលដ្ឋានសុខាភិបាលផ្សេងទៀត
- មិនប្រឌិតឬបំភ្លៃការពិតប្រាសចាកពីក្រមសីលធម៌វិជ្ជាជីវៈសុខាភិបាលធ្វើជាមុខជំនួញផ្ទាល់ខ្លួនណាមួយ តាមរូបភាពផ្សព្វផ្សាយដោយផ្ទាល់ ឬដោយប្រយោល តាមរូបភាពសម្ភាសអតិថិជន ឬអ្នកជំងឺ
- មិនផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្ម ដែលប៉ះពាល់ដល់ក្រមសីលធម៌វិជ្ជាជីវៈ
- មិនផ្សព្វផ្សាយ ឬការផ្សាយផ្ទាល់(LIVE) ឬផ្សាយបន្តផ្ទាល់នានា ឬចែករំលែកបន្ត(SHARE) ជាសាធារណៈ អំពីរោគសញ្ញាគ្លីនិកនៃជំងឺ និងវិធីព្យាបាលណាមួយ ដែលមានលក្ខណៈបំផ្លើស បោកប្រាស់អតិថិជន ឬមានលក្ខណៈពាណិជ្ជកម្មដែលប៉ះពាល់ដល់ក្រមសីលធម៌វិជ្ជាជីវៈ
- គោរពតាមអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។

ក្នុងករណីដែលសេវា...........................................................ខ្ញុំបាទ-នាងខ្ញុំប្រព្រឹត្តខុសពីការណែនាំរបស់ក្រសួងសុខាភិបាល ខ្ញុំបាទ-នាងខ្ញុំយល់ព្រមឱ្យក្រសួងសុខាភិបាលដកយកលិខិតអនុញ្ញាត...........................................................វិញដោយមិនប្រកែក ឬតវ៉ាឡើយ ព្រមទាំងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ក្រែងមិនប្រាកដ ខ្ញុំបាទ-នាងខ្ញុំ សូមផ្តិតមេដៃស្តាំបញ្ជាក់ជាភស្តុតាង។

ថ្ងៃ..........................................ខែ...............ឆ្នាំ..........................ព.ស.២៥៦.....

**សាក្សីដឹងឮ**

ថ្ងៃទី.............ខែ......................ឆ្នាំ២០២.....

**ហត្ថលេខា និង ឈ្មោះ**

.........................................ថ្ងៃទី............ខែ......................ឆ្នាំ២០២.....

**ស្នាមមេដៃស្តាំ និង ឈ្មោះ**

លេខទូរស័ព្ទ:..........................................